00422577

លេខ / No: D 263/1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

Kingdom of Cambodia
Nation Religion King

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 01 / 2010
ម៉ោង (Time/Heure): 10:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ការិយាល័យសហចៅក្រមស៊ើបអង្កេត

**Office of the Co-Investigating Judges**

**Bureau des Co-juges d'instruction**

លេខសំណុំរឿង: ០០២/១៩-០៩-២០០៧-អ.វ.ត.ក..-ក.ស.ច.ស.

ចំពោះមុខ ៖ ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE (ម៉ាសែល ឡឺម៉ុង)

កាលបរិច្ឆេទ៖ ៣១ ខែធ្នូ ឆ្នាំ ២០០៩

ភាសាដើម៖ ខ្មែរ

ចំណាត់ថ្នាក់ឯកសារ៖ សម្ងាត់

**Declassified to Public**
**12 April 2013**

# ដីកាសម្រេចបដិសេធសំណើសុំមោឃភាព និងសំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធីធ្វើឡើងដោយ អៀង ធីរិទ្ធ

**សហព្រះរាជអាជ្ញា**

អ្នកស្រី ជា លាង

លោក Andrew CAYLEY

**ជនត្រូវចោទ**

នួន ជា　　ខៀវ សំផន

អៀង សារី　　កាំង ហ្គេកអ៊ាវ

អៀង ធីរិទ្ធ　　ហេី/ ឌុច

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

នី ច័ន្ទឌី　ឡោ ជុនធី
គង់ ពិសី ហុង គឹមសួន
យ៉ុង ផានិត គីម ម៉េងឃី
ម៉ុច សុវណ្ណារី　ស៊ីន សុវន
ជេត វណ្ណលី　ពេជ អង្គ
Silke STUDZINSKY
Phillipe CANONNE

Elizabeth Rabesandratana
Pierre-Olivier SUR
Mahdev MOHAN
Olivier BAHOUGNE
David BLACKMAN
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Lyma Thuy Nguyen
Marie Guiraud

**មេធាវីការពារក្តី**

សុន អរុណ　Michiel PESTMAN
អាង ឧត្តម Michael G.KARNAVAS
ផាត់ ពៅសៀង Diana ELLIS
ស សូវាន Jacques VERGES
ការ សាវុត្ថ François ROUX
Marie-Paule CANIZARES

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04 / 01 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**យើង យូ ប៊ុនឡេង** និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក.”)

**បានឃើញ**ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ (“ច្បាប់ស្តីពី អ.វ.ត.ក”)

**បានឃើញ**វិធាន ២១ វិធាន ២៨ វិធាន ៥៦ វិធាន ៧៦ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (វិធានផ្ទៃក្នុង)

**បានឃើញ**ការបន្តការស៊ើបសួរលើឈ្មោះ **អៀង ធីរិទ្ធ** និង **ជនដទៃ** ដែលត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យលើ**បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការវាយប្រហារលើសាសនា** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាម មាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២០៩ មាត្រា ២១០ មាត្រា ៥០០ មាត្រា ៥០១ មាត្រា ៥០៣ ដល់ មាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦

**បានឃើញ**សំណើរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ (មេធាវីការពារក្តី) ចុះថ្ងៃទី ៧ ធ្នូ ឆ្នាំ ២០០៩ (D263) ស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេត ស្នើទៅអង្គបុរេជំនុំជម្រះឲ្យធ្វើមោឃភាពលើកិច្ចស៊ើបសួរទាំងអស់

**បានឃើញ**សំណើរបស់មេធាវីការពារក្តី ចុះថ្ងៃទី ៧ ធ្នូ ឆ្នាំ ២០០៩ (D264) ស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេត *“ផ្អាកនីតិវិធីដោយមូលហេតុរំលោភនីតិវិធី”*

**បានឃើញ** លិខិតផ្ទេរសិទ្ធិចុះហត្ថលេខាជូនលោកចៅក្រម យូ ប៊ុនឡេង ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០០៩

## ការរំលឹកឡើងវិញពីនីតិវិធី និងការកត់សំគាល់របស់មេធាវីការពារក្តី

១. នៅថ្ងៃទី ៧ ធ្នូ ឆ្នាំ ២០០៩ មេធាវីការពារក្តី បានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ស្នើទៅអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃភាពនីតិវិធីនៃកិច្ចស៊ើបសួរទាំងអស់ ("សំណើសុំមោឃភាព") ដោយអនុវត្តតាមវិធាន ៤៨ និងវិធាន ៧៦(២) នៃវិធានផ្ទៃក្នុង និងឱ្យសម្រេចផ្អាកនីតិវិធីដោយមូលហេតុរំលោភនីតិវិធី ("សំណើសុំផ្អាក") ជាពិសេសអនុវត្តទ្រឹស្តី *"មូលហេតុរំលោភនីតិវិធី"* ព្រមទាំងអត្ថបទផ្សេងទៀតដែលភ្ជាប់នៅក្នុងឧបសម្ព័ន្ធ។

២. នៅក្នុងសំណើសុំមោឃភាព[1] មេធាវីការពារក្តីអះអាងថា *"ភាពគ្មានអនាគតិដែលស្តែងឱ្យឃើញតាមរយៈការថ្លែងរបស់លោកចៅក្រម Lemonde ត្រូវបានយោងដោយ [លោក Bastin] ...ការរំលោភទៅលើការបែងចែកមុខងាររវាងអាជ្ញាធរទទួលបន្ទុកការចោទប្រកាន់ និងអាជ្ញាធរទទួលបន្ទុកការវិនិច្ឆ័យទោស។ ផ្នែកអន្តរជាតិនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបិទបាំងព័ត៌មានពីផ្នែកជាតិនៃការិយាល័យនេះ និងការរំលោភទៅលើគោលការណ៍សម្ងាត់"*។ នៅក្នុងសំណើសុំផ្អាក[2] ក្រៅពីការចោទប្រកាន់ទាំងនេះ មេធាវីការពារក្តីបានលើកឡើងពី *"ការបកស្រាយមិនត្រឹមត្រូវពីសំណាក់ ក.ស.ច.ស ទៅលើហេតុផលរបស់ខ្លួនឯង ហើយការអត្ថាធិប្បាយរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ទាំងអស់បង្កើតឱ្យមានការបាត់បង់ជំនឿទុកចិត្តទៅលើការស៊ើបសួររបស់តុលាការនេះ"*។

៣. ដើម្បីគាំទ្រដល់សំណើសុំរបស់ខ្លួន មេធាវីការពារក្តីសំអាងលើ៖

- សេចក្តីប្រកាសរបស់លោក Wayne Bastin[3] ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០០៩ ដែលត្រូវបានផ្តល់ជូនដើម្បីគាំទ្រដល់បណ្តឹងជិតចិត្តចំពោះចៅក្រម Lemonde

---

[1] D263, **សំណើសុំឱ្យសហចៅក្រមស៊ើបអង្កេត ស្នើទៅអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃភាពលើកិច្ចស៊ើបសួរទាំងអស់** ចុះថ្ងៃទី ៧ ធ្នូ ឆ្នាំ ២០០៩ 00411924-00411940 កថា. ៥២ (បន្ទាប់ទៅនេះ គឺ "D263 សំណើសុំមោឃភាព")

[2] D264,**សំណើរបស់មេធាវីការពារក្តី ចុះថ្ងៃទី ៧ ធ្នូ ឆ្នាំ ២០០៩ ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ផ្អាកនីតិវិធីដោយមូលហេតុរំលោភនីតិវិធី** 00412236-00412252 កថា. ៥២ បន្ទាប់ទៅនេះ គឺ "D264 សំណើសុំផ្អាកនីតិវិធី"។

[3] D263 **សំណើសុំមោឃភាព** កថា. ៤។ D264 សំណើសុំផ្អាកនីតិ វិធី កថា. ៣។

ធ្វើឡើងដោយមេធាវីការពារក្តី អៀង សារី ដោយផ្អែកទៅលើការចោទប្រកាន់ដូចគ្នា ("សេចក្តីប្រកាសលើកទីមួយ")

- ចម្លើយតបជាលាយល័ក្ខអក្សររបស់លោកចៅក្រម Lemonde[4] និង
- សេចក្តីប្រកាសបន្ថែមរបស់លោក Wayne Bastin[5] ចុះថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០០៩ ("សេចក្តីប្រកាសលើកទីពីរ")

៤. ដើម្បីគាំទ្រដល់សំណើសុំផ្អាករបស់ខ្លួន មេធាវីការពារក្តី ក៏សំអាងផងដែរលើ៖

- សន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា នៅខេត្តតាកែវ កាលពីថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០០៩
- "ការចូលជ្រៀតជ្រែក" របស់ចៅក្រម Lemonde នៅក្នុងការវាយតំលៃលើការងាររបស់បុគ្គលិកមួយរូប
- ដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរដែលមានគោលបំណងស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម (SMD)[6]
- ដីកាសម្រេចបន្តការឃុំខ្លួន អៀង ធីរិទ្ធ[7]។

៥. មេធាវីការពារក្តី បញ្ជាក់ថា ស្របពេលជាមួយគ្នានេះ ខ្លួនក៏បានដាក់ពាក្យបណ្តឹងជំទាស់ចំពោះចៅក្រម Lemonde ទៅអង្គបុរេជំនុំជម្រះ ផងដែរ កាលពីថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០០៩[8]។

៦. ដោយផ្អែកទៅលើចំនុចទាំងអស់នេះហើយ ទើបមេធាវីការពារក្តីស្នើសុំសហចៅក្រមស៊ើបអង្កេត *"ស្នើទៅអង្គបុរេជំនុំជម្រះឲ្យធ្វើមោឃភាពលើកិច្ចស៊ើបសួរទាំងអស់"*[9] និង *"ផ្អាក*

---

[4] សំណុំរឿងលេខ 002/09-10-2009-ECCC/OCIJ (PTC01) និង 002/13-10-2009-ECCC/OCIJ (PTC02), 4, **ចម្លើយតបតែមួយរបស់សហចៅក្រមស៊ើបអង្កេត Marcel Lemonde តបទៅនឹងបណ្តឹងជំទាស់ ធ្វើឡើងដោយ អៀង សារីនិង ខៀវ សំផន** ៥ វិច្ឆិកា ២០០៩ 00399417-00399430.

[5] D263 **សំណើសុំមោឃភាព** កថា. ៥។ D264 **សំណើសុំផ្អាកនីតិវិធី** កថា. ៣។

[6] D164/2, **ដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរក្នុងគោលបំណងស្វែងរកភស្តុតាងដោះបន្ទុកដែលមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួម** ១៩ មិថុនា ២០០៩ 00343279-00343286។

[7] C20/8, **ដីកាសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្ន** ១០ វិច្ឆិកា ២០០៩ 00399346-00399357។

[8] D263 **សំណើសុំមោឃភាព** កថា. ១០។

[9] D263 **សំណើសុំមោឃភាព** កថា. ៥៩។

*នីតិវិធី*"[10] ស្របទៅតាមទ្រឹស្តី *"មូលហេតុរំលោភនីតិវិធី"* ដែលបានលើកឡើងនៅក្នុងកថាខណ្ឌ ៧-១៦ នៃសំណើសុំផ្អាកនីតិវិធី។

**សំអាងហេតុនៃសេចក្តីសម្រេច**

***ការពិចារណាជាបឋម***

៧. ជាបឋម សហចៅក្រមស៊ើបអង្កេត សង្កេតឃើញថា ការលាយឡំនៃនីតិវិធីឧប្បត្តិហេតុធ្វើឱ្យមានការភ័ន្តច្រឡំផ្លូវច្បាប់ដោយមេធាវីការពារក្តីខ្លួនឯង ពីព្រោះសំណើសុំមោឃភាព[11] បានយោងទៅលើទឡ្ហីករណ៍ដែលមាននៅក្នុងពាក្យបណ្តឹងជិតចិត្ត ដែលមានចៅក្រមមួយរូបនៅក្នុងចំណោមសហចៅក្រមស៊ើបអង្កេតទាំងពីររូប មិនបានដឹងទាល់តែសោះ ដោយសារវាពាក់ព័ន្ធតែជាមួយនឹងចៅក្រមមួយរូបផ្សេងទៀត។ ការលាយឡំគ្នាបែបនេះនាំឱ្យមានការលំបាកចំពោះសហចៅក្រមស៊ើបអង្កេតក្នុងការឆ្លើយតប មិនថាជាការឆ្លើយតបរួមគ្នា ឬដោយឡែកពីគ្នានោះទេ ហើយនាំឱ្យមានការលំបាកផងដែរចំពោះទឡ្ហីករណ៍នៃអង្គហេតុដែលពាក់ព័ន្ធនឹងសហចៅក្រមស៊ើបអង្កេតមួយរូប ឬសហចៅក្រមស៊ើបអង្កេតទាំងពីរ។

៨. ទោះបីជាវាមានភាពមិនប្រក្រតីដូច្នេះក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេត នឹងធ្វើការឆ្លើយតបរួមគ្នាចំពោះទឡ្ហីករណ៍ទាំងអស់ដែលបានលើកឡើងដោយមេធាវីការពារក្តី ទាំងនៅក្នុងសំណើសុំមោឃភាព ទាំងសំណើសុំផ្អាកនីតិវិធី ជាមួយនឹងអំណះអំណាងរួមគ្នា ឬដោយឡែកពីគ្នា អាស្រ័យទៅលើខ្លឹមសារនៃទឡ្ហីករណ៍ដែលបានលើកឡើង។ ហេតុដូចនេះ រាល់អំណះអំណាង ដែលមិនបានបញ្ជាក់ថាជាអំណះអំណាងផ្ទាល់ខ្លួនរបស់សហចៅក្រមមួយរូបណាទេ វាគឺជាអំណះអំណាងដែលត្រូវបានសម្រេចរួមគ្នាដោយសហចៅក្រមស៊ើបអង្កេតទាំងពីររូប។

---

[10] D264 **សំណើសុំផ្អាកនីតិវិធី** កថា. ៦១។

[11] D263 **សំណើសុំមោឃភាព** កថា. ១០។

00422582



ក. សំណើសុំមោឃភាព

***ច្បាប់ដែលត្រូវអនុវត្ត***

៩. លើកលែងតែមានការចែងច្បាស់អំពីករណីធ្វើមោឃភាពដោយសារខុសនឹងទម្រង់ វិការៈនៃនីតិវិធី ដែលអាចបណ្តាលឲ្យមានមោឃភាពកិច្ចដំណើរការនីតិវិធីមួយ ឬច្រើនបាន គឺតែចំពោះករណីវិការៈនោះរំលោភសិទ្ធិរបស់មេធាវីការពារក្តី ដូចមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយប៉ុណ្ណោះ[12]។ សិទ្ធិទាំងនេះត្រូវបានចែងផងដែរនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង។

១០. យោងតាមវិធាន ៤៨ នៃវិធានផ្ទៃក្នុង *"កិច្ចស៊ើបសួរ ឬ កិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈតែចំពោះករណីមិនគោរពវិធានបញ្ញត្តិដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំប៉ុណ្ណោះ"*។ ដូច្នេះ នៅពេលទទួលបានសំណុំសុំមោឃភាព សហចៅក្រមស៊ើបអង្កេត ត្រូវ ៖

- ពិនិត្យមើលពីវត្តមាននៃវិការៈនៃនីតិវិធី ហើយ
- ប្រសិនបើមានវិការៈនៃនីតិវិធី ពិនិត្យមើល ថាតើវិការៈនេះ ប៉ះពាល់ ឬមិនប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធ

១១. ដោយផ្អែកលើគោលការណ៍ទាំងនេះហើយ ដែលយើងចាំបាច់ត្រូវពិនិត្យមើល ថាតើក្នុងករណីនេះ សំណើរបស់មេធាវីការពារក្តី មានលក្ខណៈត្រឹមត្រូវដែរ ឬទេ។

***សេចក្តីប្រកាសលើកទីមួយរបស់លោក Bastin***

១២. កថាខ័ណ្ឌ ១២ ដល់ ២២ នៃសំណើសុំមោឃភាព[13] សំអាងការចោទប្រកាន់ពីភាពលំអៀង[14]ទៅលើ "អង្គហេតុ" តែមួយ៖ សំដីដែលលោកចៅក្រម Lemonde បាននិយាយ

---

[12] សំណុំរឿងលេខ ០០២/១៩.០៩.២០០៧ អវតក/កសចស (អបជ ០៦) D55/I/8 **សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាបដិសេធពាក្យសុំមោឃភាព** ២៦ សីហា ២០០៨ 00225149-00225160, កថា. ៣៤-៤១។

[13] និងប្រើពាក្យពេចន៍ស្ទើរតែដូចគ្នា ដែលមាននៅក្នុងកថាខ័ណ្ឌ ១៧-២៣ នៃសំណើសុំផ្អាកនីតិវិធី។

00422583



នៅខែធ្នូ ឆ្នាំ ២០០៩ នៅអំឡុងពេលនៃការជួបប្រជុំមួយនៅផ្ទះរបស់គាត់ ជាមួយនឹងបុគ្គលិកជាច្រើននៃការិយាល័យសហចៅក្រមស៊ើបអង្កេត។

១៣. ប៉ុន្តែ នៅក្នុងសាលដីកាចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០០៩ អង្គបុរេជំនុំជម្រះបានបដិសេធបណ្តឹងជិតចិត្តដែលសំអាងទៅលើហេតុផលដដែល ដោយបានបញ្ជាក់ថា *"ជនត្រូវចោទ មិនអាចត្រូវបានលើកលែងពីបន្ទុកស្វែងរកភស្តុតាងដែលធ្លាក់ទៅលើខ្លួនទេ នៅក្នុងករណីនេះ"*[15] ។

១៤. មេធាវីការពារក្តី ដែលអះអាងថា ការចោទប្រកាន់ពីភាពលំអៀង *"បានផ្តល់មូលដ្ឋានគ្រប់គ្រាន់សម្រាប់បណ្តឹងសុំមោឃភាពនាពេលនេះ"*[16] នោះ ត្រូវមានបន្ទុកដូចគ្នាក្នុងការស្វែងរកភស្តុតាងដែលធ្លាក់ទៅលើខ្លួន។ ហេតុដូច្នេះ ពាក្យសុំមោឃភាព និងសំណើសុំផ្អាកនីតិវិធី ត្រូវបានបដិសេធចោល ដោយហេតុផលដូចគ្នានឹងបណ្តឹងជិតចិត្តដែរ និងមិនចាំបាច់មានការពិនិត្យបន្ថែមទៀតទេ។

***សេចក្តីប្រកាសទីពីររបស់ Bastin***

១៥. មុននឹងធ្វើការឆ្លើយតបទៅនឹងអំណះអំណាងនីមួយៗ ដែលលើកឡើងនៅក្នុងសេចក្តីប្រកាសទីពីររបស់លោក Wayne Bastin យើងបានកត់សម្គាល់ឃើញថា វាជារឿងដែលគួរឲ្យងឿងឆ្ងល់មួយ នៅពេលដែលបានអានសំណេររបស់មេធាវីការពារក្តី ដែលលើកឡើងថា អំណះអំណាងអស់ទាំងនេះត្រូវបាន "*ចាត់ទុកថាជាការពិត សម្រាប់តម្រូវការនៃបណ្តឹង*"[17]

---

[14] ទន្ទឹមនឹងនេះ សចស កត់សំគាល់ឃើញថា នៅកថាខ័ណ្ឌ ១៥ នៃសំណើសុំមោឃភាព មេធាវីការពារក្តី លើកឡើងដោយភាន់ច្រឡំ ដោយអះអាងថា *"ការអត្ថាធិប្បាយបង្ហាញពី<u>ភាពលំអៀង</u>"* (មានការគូសបន្ទាត់ពីក្រោមបន្ថែម)

[15] សំណុំរឿងលេខ ០០២/១៩.០៩.២០០៧ អវតក/កសចស (អបជ ០៧) **សាលដីកាលើបណ្តឹងជិតចិត្តរបស់ អៀង សារី ចំពោះសហចៅក្រមស៊ើបអង្កេត Marcel Lemonde** ៩ ធ្នូ ២០០៩ 00411300-00411309 កថា. ២៦។

[16] D263 **សំណើសុំមោឃភាព** កថា. ១៨។

[17] *"សម្រាប់គោលបំណងនៃសំណើនេះ សច្ចភាពនៃការចោទប្រកាន់ដែលមាននៅក្នុងសេចក្តីថ្លែងការណ៍ទាំងពីររបស់លោក Bastin នឹងត្រូវបានសន្មតទុកជាមុន"* : D263, **សំណើសុំមោឃភាព,** កថាខណ្ឌទី៨។ D264, **សំណើសុំផ្អាកនីតិវិធី** កថាខណ្ឌទី៥

ដោយគ្មានដែនកំណត់ណាមួយឡើយ។ អង្គបុរេជំនុំជម្រះមានការស្ទាក់ស្ទើរចិត្តនៅឡើយនៅក្នុងការកំណត់ទម្ងន់ដែលត្រូវផ្តល់ឱ្យដល់ សេចក្តីប្រកាសប្រភេទនេះ[18]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សូមឆ្លៀតយកឱកាសនេះបញ្ជាក់ថា មេធាវីការពារក្តី ត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់មុននឹងផ្តល់ជំនឿណាមួយទៅលើគំនិតលោក Bastin ដែលលោកខកខានមិនបានគោរពនូវកាតព្វកិច្ចរបស់ខ្លួនក្នុងការរក្សាការសម្ងាត់នោះ (កាតព្វកិច្ចនេះត្រូវបានចែងយ៉ាងច្បាស់ ដើម្បីធានាថា អ.វ.ត.ក និងបុគ្គលិកទាំងឡាយដែលបម្រើការនៅក្នុងក្របខណ្ឌនៃ អ.វ.ត.ក អាចបំពេញតួនាទីសំខាន់ៗរបស់ខ្លួនបានដោយគ្មានភ័យខ្លាចចំពោះការគម្រាមកំហែង ដោយហេតុថាពាក្យសម្តីនិងទង្វើរបស់ពួកគេត្រូវបានផ្សព្វផ្សាយឱ្យសាធារណៈជនបានដឹងនៅក្រៅអំពីបរិបទទាំងមូល នឹងអាចត្រូវបានយកទៅបកស្រាយខុស ឬផ្ទុយអំពីកម្មវត្ថុនៃពាក្យសម្តី ឬទង្វើនោះ។

១៦. សហចៅក្រមស៊ើបអង្កេតសង្កេតឃើញថា លោក Bastin បានរង់ចាំអស់រយៈពេលលើសពី២ខែ ដើម្បីធ្វើរបាយការណ៍អំពីអ្វីដែលលោកចៅក្រម Lemonde បាននិយាយ នៅក្នុងអង្គប្រជុំមួយកាលពីខែសីហា ឆ្នាំ២០០៩។ គាត់ត្រូវរង់ចាំអស់រយៈពេល២ខែទៀត ដើម្បីធ្វើ "ការលាតត្រដាង" ថ្មីមួយទៀត ដោយគ្មាននរណាម្នាក់អាចយល់បានថា ហេតុដូចម្តេចនិងនៅក្នុងលក្ខខណ្ឌណាខ្លះ ដែលសេចក្តីប្រកាសទាំងពីរនេះត្រូវបានដាក់ជូនក្រុមមេធាវីការពារក្តី ហើយបែរជាមិនត្រូវបានដាក់ជូនស្ថាប័នមានសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិទៅវិញ។ម្យ៉ាងទៀត មេធាវីការពារក្តីក៏មិនបានធ្វើការពន្យល់ណាមួយអំពីមូលហេតុដែលថា សេចក្តីប្រកាសលើកទីពីររបស់លោក Bastin ដែលមេធាវីការពារទទួលបានកាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៩[19] ត្រូវបានប្រកាសជាសាធារណៈក្នុងពេលដំណាលគ្នានឹងការដាក់ពាក្យបណ្តឹងដែលមានមូលដ្ឋានផ្អែកទៅលើសេចក្តីប្រកាសនោះ[20]។

១៧. ដោយកំណត់សម្គាល់បឋមទាំងនេះត្រូវបានធ្វើរួចរាល់ហើយនោះ ដូច្នេះយើងត្រូវធ្វើការសិក្សាទៅលើអត្ថន័យនៃសេចក្តីប្រកាសទីពីរ ដោយពិនិត្យជាបន្តបន្ទាប់ទៅលើបញ្ហានានាដែលបានលើកឡើង។

---

[18] សំណុំរឿងលេខ ០០២/១៩.០៩.២០០៧ អវតក/កសចស (អបជ០៧) **សាលដីកាលើសំណើជំទាស់ចិត្តរបស់ អៀង សារី ចំពោះសហចៅក្រមស៊ើបអង្កេត Marcel Lemonde ៩ ធ្នូ ២០០៩** 00411300-00411309 កថាខណ្ឌទី២០។

[19] D263 **សំណើសុំមោឃភាព**, កថាខណ្ឌទី៥។

[20] សារព័ត៌មាន Cambodia Daily ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩។

***អំពីកិច្ចសហប្រតិបត្តិការរវាងសហចៅក្រមស៊ើបអង្កេត***

១៨. មេធាវីការពារក្តី បានលើកឡើងថា នៅក្នុងកាលៈទេសៈផ្សេងៗគ្នា និងនៅក្នុងរូបភាពខុសៗគ្នា ការិយាល័យសហចៅក្រមស៊ើបអង្កេត "ខាងអន្តរជាតិ" បានបិទបាំងនូវព័ត៌មានមួយចំនួនដោយមិនបានធ្វើការចែកចាយទៅ "ខាងជាតិ"[21] ទេ (ដោយមិនបានបញ្ជាក់អំពីមូលហេតុដែលធ្វើឱ្យ "ការលាក់កំបាំងព័ត៌មានទាំងនេះ" អាចបង្កើតជាមោឃភាពចំពោះនីតិវិធីមួយ ឬច្រើនផ្នែកនោះ)។ នៅពេលខ្លះ ភាពសមហេតុសមផលនៃអំណះអំណាងរបស់មេធាវីការពារក្តី មានការលំបាកក្នុងការទទួលយក ដោយហេតុថា មេធាវីការពារក្តីបានសង្កត់ធ្ងន់ទីមួយទៅលើសារៈសំខាន់នៃការរួមចំណែករបស់បុគ្គលិកកម្ពុជាដើម្បីធានាឱ្យមានសច្ចៈភាពនៃកិច្ចស៊ើបអង្កេត[22] និងក្នុងករណីទីពីរ មេធាវីការពារមានការព្រួយបារម្ភទាក់ទិនទៅនឹងលទ្ធភាពនៃការអន្តរាគមន៍ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាចូលទៅក្នុងកិច្ចការរបស់ អ.វ.ត.ក[23] ដោយធ្វើការចោទប្រកាន់ថា ការមិនបានចែកចាយព័ត៌មានគឺដោយសារកង្វះទំនុកចិត្តរបស់ចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះចៅក្រមស៊ើបអង្កេតកម្ពុជា។ ទោះជាក្នុងករណីណាក៏ដោយ ភាពសង្ស័យអំពីការលាក់កំបាំងព័ត៌មានដោយចេតនានេះ ត្រូវតែបានទម្លុះ។

១៩. ច្បាប់ និងកិច្ចព្រមព្រៀង ស្តីអំពីការបង្កើត អ.វ.ត.ក បានបង្កើតឱ្យមានប្រព័ន្ធនៃសហចៅក្រមស៊ើបអង្កេត ដែលចៅក្រមស៊ើបអង្កេតនីមួយៗមានអំណាចដូចគ្នា។ ដូចដែលមេធាវីការពារក្តីបានយល់ឃើញថា *"ទ្រឹស្តីនៃការធ្វើសេចក្តីសម្រេចរួមគ្នា គឺជាលក្ខខណ្ឌសំខាន់នៃការបង្កើតតុលាការនេះ"*[24]។ ដោយហេតុថា សហចៅក្រមស៊ើបអង្កេតនីមួយៗមានអំណាចដូចគ្នា ដូច្នេះសហចៅក្រមស៊ើបអង្កេតត្រូវតែធ្វើសហប្រតិបត្តិការរវាងគ្នាដើម្បីធ្វើយ៉ាងណាឱ្យដំណើរការស៊ើបអង្កេតប្រព្រឹត្តទៅដោយមានប្រសិទ្ធិភាព។ ជាក់ស្តែងសហចៅក្រមស៊ើបអង្កេតបានបំពេញកិច្ចការនេះជាមួយគ្នាអស់រយៈពេលជាងបីឆ្នាំកន្លងមក ដោយគ្មានការលំបាកអ្វីទាំងអស់។

---

[21] D263 **សំណើសុំមោឃភាព**, កថាខណ្ឌទី៣១។ D264, **សំណើសុំផ្អាកនីតិវិធី** ,កថាខណ្ឌទី៣០ ដល់៣៣។

[22] D263 **សំណើសុំមោឃភាព**, កថាខណ្ឌទី៣៧ និង ៣៨។

[23] D263 **សំណើសុំមោឃភាព**, កថាខណ្ឌទី៥៣ ដល់៥៥។

[24] D263 **សំណើសុំមោឃភាព**, កថាខណ្ឌទី៣៤។

00422586



២០. កិច្ចសហការជាអចិន្ត្រៃយ៍រវាងសហចៅក្រមស៊ើបអង្កេតទាំងពីរនេះកើតចេញអំពីការទទួលខុសត្រូវរបស់ចៅក្រមស៊ើបអង្កេតទាំងនោះផ្ទាល់។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សូមបញ្ជាក់ថា សមាជិកម្នាក់នៃបុគ្គលិកទាំងអស់ តួយ៉ាងដូចជាលោក Bastin ដែលលោកមិនបានក្តាប់នូវគ្រប់ព័ត៌មានចាំបាច់ទាំងអស់នោះ (ម្យ៉ាងទៀត យល់មិនច្បាស់អំពីប្រព័ន្ធនីតិវិធី ដែលកំពុងអនុវត្តនៅ អ.វ.ត.ក) លោកគ្មានសមត្ថភាពធ្វើកិច្ចការជំនួសចៅក្រមស៊ើបអង្កេតក្នុងការវាយតម្លៃអំពីបែបផែនដែលតម្រូវឱ្យមានកិច្ចសហប្រតិបត្តិការជាក់ស្តែងរវាងសហចៅក្រមស៊ើបអង្កេតនោះទេ និងជាពិសេស លោកគ្មានសមត្ថភាពក្នុងការសម្រេចជំនួសសហចៅក្រមស៊ើបអង្កេតអំពីថាតើនៅក្នុងករណីណាមួយ ឬនៅពេលណាខ្លះដែលព័ត៌មានទាក់ទងដល់វិធីសាស្ត្រចម្បងក្នុងការស៊ើបសួរ ត្រូវតែដាក់ជាកម្មវត្ថុនៃកិច្ចប្រជុំពិភាក្សារវាងសហចៅក្រមស៊ើបអង្កេតនោះទេ។

២១. ម្យ៉ាងវិញទៀត សហចៅក្រមស៊ើបអង្កេតសូមបញ្ជាក់ថា ក្នុងការអនុវត្តជាក់ស្តែងនៅក្នុង ក.ស.ច.ស រាល់ការងារដែលបានធ្វើជាឯកតោភាគីដោយភាគីខាងជាតិ ឬភាគីខាងអន្តរជាតិ ត្រូវបានចាត់ទុកថាជាការងារត្រៀមរៀបចំប៉ុណ្ណោះ និងថារាល់កិច្ចស៊ើបសួរទាំងអស់ត្រូវបានបំពេញរួមគ្នាដោយបុគ្គលិកជាតិ និងបុគ្គលិកអន្តរជាតិ ក្រោមការដឹកនាំ ការពិភាក្សាជាមុន និងសេចក្តីសម្រេចរួមគ្នារបស់សហចៅក្រមស៊ើបអង្កេតទាំងពីរ។ ចំណែកឯកិច្ចពិភាក្សារវាងចៅក្រមដែលបានធ្វើមុនសេចក្តីសម្រេចនានា គឺមិនមែនចៅក្រមណាម្នាក់មានឥទ្ធិពលទៅលើចៅក្រមម្នាក់ទៀតទេ (ដោយថា ម្នាក់ៗគឺឯករាជ្យ) ប៉ុន្តែ វាជាការជូនព័ត៌មានគ្នាទៅវិញទៅមកអំពីគោលការណ៍ច្បាប់ និងគោលការណ៍យុត្តិធម៌ ដែលត្រូវប្រកាន់យកក្នុងការធ្វើសេចក្តីសម្រេច។

***អំពីក្រុមបុគ្គលិកផ្នែកខ្សែភាពយន្តឯកសារ***

២២. ដោយយោងតែទៅលើសេចក្តីប្រកាសនានារបស់លោក Bastin តែមួយគត់ មេធាវីការពារក្តី បានលើកឡើងថា លក្ខខណ្ឌទាំងឡាយនៃការផលិតខ្សែភាពយន្តឯកសារស្តីអំពីការស៊ើបអង្កេតទៅលើរឿងក្តីខ្មែរក្រហម គឺជាការរំលោភលើការរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរ បន្ថែមពីលើករណីនៃការបង្ហាញនូវ "ភាពលាក់កំបាំងព័ត៌មានដោយចេតនា" ដូចបានលើកឡើងក្នុងកថាខណ្ឌទី១៩ រហូត ដល់ទី២១ ខាងលើ។

២៣. គួររំលឹកផងដែរថា នៅក្នុងក្របខណ្ឌនៃកិច្ចសន្យាដែលបានចុះហត្ថលេខាជាមួយការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក មានក្រុមអ្នកថតខ្សែភាពយន្តឯកសារមួយក្រុមត្រូវបានអនុញ្ញាតឱ្យផលិតខ្សែភាពយន្តមួយដែលមានគោលដៅអប់រំ និងប្រវត្តិសាស្ត្រ។ វាជាខ្សែភាពយន្តមួយដែលអនុញ្ញាតឱ្យក្រុមមេធាវីការពារក្តីទាំងអស់អាចចូលរួមបាន ប្រសិនណាខ្លួនមានបំណងចូលរួម (មានក្រុមមេធាវីការពារក្តីប្រហែលជាពាក់កណ្តាលបានចូលរួមថត)។

២៤. កិច្ចសន្យានេះ បានទទួលការព្រមព្រៀងពីសំណាក់សហចៅក្រមស៊ើបអង្កេតទាំងពីរផងដែរ។ កិច្ចសន្យាបានចែងយ៉ាងច្បាស់ថា ខ្សែភាពយន្តនោះនឹងត្រូវបានធ្វើការផ្សព្វផ្សាយដរាបណាការជំនុំជម្រះសេចក្តីទាំងអស់ត្រូវបានបញ្ចប់ និងក្រោយពីបានទទួលការត្រួតពិនិត្យពីសំណាក់ចៅក្រម ដែលគាត់មានសិទ្ធិស្នើសុំឱ្យមានការកែប្រែផងដែរ។ អ្នកថតខ្សែភាពយន្តឯកសារត្រូវគោរពនូវខសន្យានៃការថែរក្សាការសម្ងាត់ ក្រោយពីពេលដែលខ្លួនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចស៊ើបសួរនោះ។ កិច្ចសន្យាបានចែងយ៉ាងច្បាស់ថា អ្នកផលិតខ្សែភាពយន្តត្រូវស្នើសុំការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីសំណាក់ជនដែលត្រូវបានសម្ភាសន៍ ឬជនដែលត្រូវបានចាត់តាំងឱ្យសម្តែងក្នុងខ្សែភាពយន្តនោះ ជាពិសេសគូភាគីនៃរឿងក្តី ជនរងគ្រោះ និងសាក្សី ទោះបីជាពួកគេទាំងនេះមិនបានបញ្ចេញមតិនៅក្នុងខ្សែភាពយន្តនោះក៏ដោយ។ ដូច្នេះ វាគ្មានភាពសមហេតុសមផលទាល់តែសោះ ដែលថាចៅក្រមស៊ើបអង្កេតអន្តរជាតិ “*បានអនុញ្ញាតិឱ្យក្រុមអ្នកថតខ្សែភាពយន្តឯកសារ ថតជាសម្ងាត់នូវឈុតឆាកនៃការស្តាប់យកចម្លើយសាក្សី*” នោះ។

២៥. ការអនុញ្ញាតឱ្យក្រុមអ្នកថតខ្សែភាពយន្តឯកសារអាចចូលរួមនៅក្នុងកិច្ចស៊ើបអង្កេត និងអាចទទួលបាននូវសំណុំឯកសារស៊ើបអង្កេតនានា គឺជាការអនុវត្តន៍អំណាចឆន្ទានុសិទ្ធិ ដូចមានចែងក្នុង វិធាន ៥៦ (២) (ខ) នៃវិធានផ្ទៃក្នុង ហើយទង្វើនេះមិនត្រូវបានចាត់ទុកថាជា “ការផ្សព្វផ្សាយព័ត៌មានទៅតតិយជនឡើយ” ដូចដែលមេធាវីការពារបានលើកឡើងស្រាប់។ សហចៅ-ក្រមស៊ើបអង្កេតទាំងពីរនាក់បានសន្និដ្ឋានថា គម្រោងនេះគឺមានលក្ខណៈសមស្របទៅតាមបទប្បញ្ញត្តិវិធានផ្ទៃក្នុង ហើយវាក៏បានឆ្លើយតបទៅនឹងសេចក្តីទាមទារនៃយុត្តិធម៌ចំពោះការខូចខាតនៅក្នុងក្របខ័ណ្ឌនៃរឿងក្តីមួយដែលមានវិសាលភាពជាប្រវត្តិសាស្ត្រ ហើយបានធានាដល់ការរក្សាការសម្ងាត់នៃកិច្ចស៊ើបអង្កេតនៅក្នុងអំឡុងពេលនៃការត្រៀមរៀបចំកាត់ទោសដោយសង្ឃឹមជឿជាក់ថា ពន្លឺនៃសច្ចភាពនឹងត្រូវបានបំភ្លឺនៅក្នុងសម័យកាលដ៏សំខាន់នៃប្រវត្តិសាស្ត្រ

របស់កម្ពុជា បន្ទាប់ពីការបិទនូវនីតិវិធីទាំងឡាយ ពោលគឺនៅក្នុងពេលមួយដែលសិទ្ធិរបស់មេធាវីការពារក្តីលែងចោទជាបញ្ហាទៀតនោះ។

***អំពីការបញ្ជូនឯកសារមួយរបស់ការិយាល័យសហព្រះរាជអាជ្ញា***

២៦. មេធាវីការពារក្តីមានការមិនពេញចិត្ត ចំពោះការផ្តល់ "ឯកសារមួយ" ទៅខាងអន្តរជាតិនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយលោក Craig Etcheson អ្នកស៊ើបអង្កេតប្រចាំនៅការិយាល័យសហព្រះរាជអាជ្ញា។ ចៅក្រមស៊ើបអង្កេតកម្ពុជាពិតជាមិនអាចអត្ថាធិប្បាយអំពីការផ្តល់ឯកសារបែបនេះទេ ដោយសារខ្លួនមិនបានដឹងពីរឿងនេះ។ ចំនែកឯ ចៅក្រមស៊ើបអង្កេតអន្តរជាតិវិញ ខ្លួនមិនដឹងថា មេធាវីការពារក្តី យោងទៅលើឯកសារណាមួយនោះទេ ពីព្រោះមេធាវីការពារក្តីមិនបានផ្តល់សេចក្តីបញ្ជាក់ណាមួយចំពោះឯកសារខាងលើនេះ ក្រៅអំពីសេចក្តីបញ្ជាក់ដែលផ្តល់ជូនដោយលោក Bastin ខ្លួនឯងផ្ទាល់ ហើយដែលសេចក្តីបញ្ជាក់ទាំងនោះទៀតសោតមានលក្ខណៈទូលំទូលាយ និងមានលក្ខណៈផ្ទុយគ្នា ដោយម្យ៉ាងបានលើកឡើងថា *"មានការបញ្ជាក់ជាច្រើនលើកច្រើនសារ ពីភាពចាំបាច់ដែលត្រូវធានាថា បុគ្គលិកកម្ពុជាមិនបានទទួលឯកសារនេះ។"* និងម្យ៉ាងទៀតថា *"ក្នុងរឿងនេះ វាមិនមានអ្វីដែលមិនត្រូវឲ្យបុគ្គលិកកម្ពុជា ឬ បុគ្គលិកផ្សេងទៀតរបស់ ក.ស.ច.ស ទទួលបានឯកសារនេះទេ"*។ ដោយផ្អែកលើកត្តាទាំងនេះហើយ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ពាក្យពេចន៍ដ៏ច្របូកច្របល់ទាំងនេះមិនអាចគាំទ្រអំណះអំណាងរបស់មេធាវីការពារក្តី ដែលបានលើកឡើងថា: *"ក.ស.ច.ស បានទទួលឯកសារក្រៅផ្លូវការមួយពីលោក Etcheson នៃការិយាល័យសហព្រះរាជអាជ្ញា ដែលនិយាយពីទីកន្លែងស៊ើបសួរជាក់លាក់ ដែលមិនមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរបន្ថែមឡើយ"*។[25]

២៧. ជាក់ស្តែង គេមិនអាចធ្វើបញ្ជាក់នូវសច្ចាធារណ៍នៃភាពអនាគតិរបស់ចៅក្រម តាមរយៈអំណះអំណាងដែលមានលក្ខណៈទូលំទូលាយនោះទេ ដូចដែលបានលើកឡើងក្នុងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិទាក់ទងដល់ចៅក្រមជាទូទៅថា "ភាពអនាគតិ និងសមធម៌នៃយុត្តិធម៌ត្រូវបានគម្រាមកំហែង ប្រសិនណាជាចៅក្រម ដែលត្រូវបានចោទប្រកាន់ដោយគ្មាន

---

[25] D263 **សំណើសុំមោឃភាព**, កថាខណ្ឌទី២៦។

00422589



មូលហេតុ និងដោយគ្មានភស្តុតាងច្បាស់លាស់ ត្រូវប្រកាសលាលែងពីរឿងក្តីនោះ”[26]។ វាជាករណីដូចគ្នាផងដែរ ប្រសិនណាជាសហចៅក្រមស៊ើបអង្កេតត្រូវបង្អាក់សកម្មភាពរបស់ខ្លួន ឬប្រសិនណាជាកិច្ចដែលគាត់បានបំពេញអាចត្រូវបានលុបចោល ដោយមូលហេតុថាមានបណ្តឹងចោទប្រកាន់ដែលគ្មានមូលដ្ឋានច្បាប់នោះ។

២៨. ជាសង្ខេបមក ការបកស្រាយលើសេចក្តីថ្លែងការណ៍លើកទីពីររបស់លោក Bastin ដែលធ្វើដោយក្រុមមេធាវីការពារក្តី គឺមិនមានមូលដ្ឋានច្បាស់លាស់ និងមានពេលខ្លះ មិនស្របទៅនឹងខ្លឹមសារនៃសេចក្តីថ្លែងការណ៍ ដោយសារថា សេចក្តីថ្លែងការណ៍នេះគ្រាន់តែបានលើកឡើងអំពីការចោទប្រកាន់ដែលមានលក្ខណៈទូលាយ និងមិនផ្ទាល់ ហើយព័ត៌មានទាំងនោះទទួលបានក្នុងលក្ខខណ្ឌ និងកាលៈទេសៈ ដែលមិនអាចឱ្យយើងជឿជាក់លើតម្លៃជាភស្តុតាងរបស់ព័ត៌មានទាំងនោះ។ ត្រូវកត់សម្គាល់ផងដែរថា ឧទាហរណ៍បើទោះជាយើងអាចបញ្ជាក់បានអំពីភាពត្រឹមត្រូវនៃសេចក្តីថ្លែងការណ៍នោះក៏ដោយ ក៏តាមរយៈការអានសេចក្តីថ្លែងការណ៍នោះ មិនអាចឱ្យយើងកំណត់បានថា កិច្ចស៊ើបសួរដែលបំពេញដោយ ក.ស.ច.ស. មិនលក្ខណៈលំអៀងនោះដែរ។

២៩. យោងតាមអ្វីដែលបានរៀបរាប់មកខាងលើ ក្រុមមេធាវីក្តីដែលបានដាក់ពាក្យបណ្តឹង មិនបានបង្ហាញឱ្យឃើញអំពីអត្ថិភាពនៃកំហុសនីតិវិធីណាមួយ ដែលអាចផ្តល់យុត្តិកម្មដល់ការធ្វើពាក្យបណ្តឹងទៅអង្គបុរេជំនុំជម្រះនោះឡើយ។

## ខ. ពាក្យបណ្តឹងសុំផ្អាកដំណើរការនីតិវិធី

***ច្បាប់ដែលត្រូវអនុវត្ត***

៣០. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា គោលការណ៍ពាក់ព័ន្ធនឹងច្បាប់ជាធរមាន ដែលត្រូវអនុវត្តចំពោះពាក្យបណ្តឹងសុំមោឃភាព និងពាក្យបណ្តឹងសុំផ្អាកដំណើរការនីតិវិធី គឺជាគោល

---

[26] សូមអាន *ព្រះរាជអាជ្ញាប្តឹងពី Zejnil Delalic et consorts,* សំណុំរឿងលេខ IT-96-21-A, សាលដីកាអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ (សាលដីកា *Célibici*) កថាខណ្ឌ ៧០៧។ មានលើកឡើងក្នុងសំណុំរឿងលេខ ០០២/០៩.១០.២០០៩ អវតក/កសចស (អបជ ០១) និង(អបជ ០២)។ **ចម្លើយតបតែមួយរបស់សហចៅក្រមស៊ើបអង្កេត Marcel LEMONDE ទៅនឹងបណ្តឹងជិតចិត្តរបស់ អៀង ធីរិទ្ធ និង ខៀវ សំផន** ចុះថ្ងៃ ទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩, 00399417-00399430 កថាខណ្ឌទី១៤។

00422590



ការណ៍តែមួយ ដោយសារថា សំណើសុំទាំងពីរប្រភេទនេះត្រូវបានធ្វើឡើងដោយផ្អែកជាសំខាន់លើ អង្គហេតុតែមួយ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ចាំបាច់ត្រូវធ្វើការឆ្លើយតបចំពោះការវិភាគ ដែលធ្វើឡើងដោយក្រុមមេធាវីការពារក្តីទាក់ទងនឹងការរំលោភនីតិវិធី។

៣១. យុត្តិសាស្ត្រ ដែលពាក់ព័ន្ធជាមួយនឹងទ្រឹស្តី "ការរំលោភនីតិវិធី" គឺមានលក្ខណៈច្បាស់លាស់៖ ការរំលោភនីតិវិធីអាចត្រូវបានគេប្រើប្រាស់តែក្នុងករណី៖

*១) ដោយសារនីតិវិធីនោះធ្វើឱ្យជនត្រូវចោទមិនទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ (ជាទូទៅពាក់ព័ន្ធជាមួយនឹងដំណើរការយឺតយ៉ាវនៃនីតិវិធី) ឬ*

*២) ដោយសារវាប៉ះពាល់ដល់ភាពយុត្តិធម៌របស់តុលាការ ដូច្នេះតម្រូវឱ្យមានការកាត់ទោសជនត្រូវចោទក្នុងកាលៈទេសៈពិសេសមួយ*[27]

៣២. នៅក្នុងសំណុំរឿងលេខ ០០១ សហចៅក្រមស៊ើបអង្កេតបានធ្វើការបញ្ជាក់ថា *"យុត្តាធិការដែលប្រើប្រាស់សញ្ញាណនេះមិនមែនមិនគិតដល់ទាល់តែសោះអំពីសមាមាត្ររវាងការរំលោភបំពានដែលត្រូវចោទប្រកាន់ និងដំណើស្រាយដែលស្នើឡើងនោះទេ ជាការពិតណាស់ដែលថានៅក្នុងរឿងក្តីនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ការបញ្ចប់ការចោទប្រកាន់អាចកើតមានបានតែនៅក្នុងករណីប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនជាប់ចោទ ជាឧទាហរណ៍យ៉ាងហោចក្នុងកំរិតអប្បបរមា ដូចអ្វីដែលបានកើតមានឡើងនៅក្នុងរឿងក្តី Toscanino។ ហេតុនេះសហចៅក្រមស៊ើបអង្កេតបានជ្រើសរើសយកដំណោះស្រាយដែលបានប្រកាន់យកនៅក្នុងរឿងក្តី Nikolic ឬ Lubanga ដែលតម្រូវថា៖ ដើម្បីអនុវត្តទ្រឹស្តីនៃការរំលោភនីតិវិធីត្រូវមានការបង្ហាញពីការរំលោភបំពានធ្ងន់ធ្ងរ និងពិតប្រាកដលើសិទ្ធិជនត្រូវចោទ"*[28]។

៣៣. ចំពោះរឿងនេះ ក្រុមមេធាវីការពារក្តីបានលើកឡើងថា ត្រូវអនុវត្តលក្ខណៈវិនិច្ឆ័យដែលមានលក្ខណៈធូរស្រាយជាងដើម្បីកំណត់អំពីអត្ថិភាពនៃការរំលោភនីតិវិធី ដែលបានកំណត់យកដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងសេចក្តីសម្រេចខាងលើនេះ ដោយហេតុថា *"ការរំលោភ*

---

[27] សភាជាន់ខ្ពស់ប្រទេសអង់គ្លេស ទល់នឹង Horseferry Road Magistrates Court Ex parte Bennett ដែលមានយោងនៅក្នុងពាក្យបណ្តឹងសុំផ្អាកដំណើរការនីតិវិធី កថា. ១២

[28] C3 ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃ ៣១ កក្កដា ២០០៧ កថា. ២១

*នីតិវិធីត្រូវបានប្រព្រឹត្តដោយស្ថាប័នមួយរបស់ អ.វ.ត.ក. ខ្លួនឯង ហើយការរំលោភនេះទៀតពាក់ព័ន្ធទៅនឹងភាពមិនត្រឹមត្រូវនៃដំណើរការនីតិវិធី ប្រឆាំងនឹងជនត្រូវចោទ ជាជាងបន្តថេរវេលានៃការឃុំខ្លួន[29]*"។ ចំពោះបញ្ហានេះ សហចៅក្រមស៊ើបអង្កេតមិនឃើញមានមូលដ្ឋានណាមួយដែលគាំទ្រដល់ការលើកឡើងដូច្នេះរបស់ក្រុមមេធាវីការពារក្តី នៅក្នុងការអនុវត្តជាអន្តរជាតិនោះទេ[30]។

៣៤. នៅក្នុងសម្មតិកម្មបែបណាក៏ដោយ ទ្រឹស្តីនៃការរំលោភនីតិវិធីមិនអាចនឹងអនុវត្តបានទេ នៅក្នុងរឿងនេះ ដោយសារថាសិទ្ធិរបស់ជនត្រូវចោទមិនត្រូវបានរំលោភបំពាននោះឡើយ។

**អង្គហេតុដែលចោទប្រកាន់**

៣៥. មធ្យោបាយតទល់ដែលបានលើកឡើងនៅក្នុងរឿងនេះ ភាគច្រើនជាមធ្យោបាយតទល់តែមួយដូចគ្នានឹងមធ្យោបាយតទល់ដែលលើកឡើងនៅក្នុងពាក្យបណ្តឹងសុំមោឃភាព៖ ពាក្យបណ្តឹងបានចម្លងយកតាមការចោទប្រកាន់នានា ដែលមាននៅក្នុងសេចក្តីថ្លែងការណ៍លើកទីមួយរបស់លោក Wayne Bastin។ ហើយពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍លើកទីពីរវិញ គឺការចោទប្រកាន់ដែលទាក់ទងនឹងការរក្សាទុកព័ត៌មានរបស់ចៅក្រមស៊ើបអង្កេតអន្តរជាតិ បញ្ហាក្រុមអ្នកថតកុន និងបញ្ហានៃការផ្តល់នូវឯកសារព័ត៌មានមួយរបស់ការិយាល័យសហព្រះរាជអាជ្ញា។ មានការឆ្លើយតបចំពោះមធ្យោបាយតទល់ទាំងនេះនៅក្នុងកថាខណ្ឌ ១២ ដល់ ២៨ ខាងលើ។

៣៦. ទោះបីជាយ៉ាងនេះក្តី ពាក្យបណ្តឹងសុំផ្អាកដំណើរការនីតិវិធីបានលើកឡើងនូវមធ្យោបាយតទល់បន្ថែម ដែលត្រូវពិនិត្យដាច់ដោយឡែក។

*ទាក់ទងនឹងការវាយតម្លៃលើការងាររបស់ លោក Stephen Heder*

---

[29] D264 ពាក្យបណ្តឹងសុំផ្អាកដំណើរការនីតិវិធី កថា. ៨

[30] សូមមើល រដ្ឋអាជ្ញា ទល់នឹង Lubanga សំណុំរឿងលេខ ICC-01/04-01/06 អង្គជំនុំជម្រះឧទ្ធរណ៍ សាលដីកាទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ Thomas Lubanga Dyilo ប្រឆាំងនឹង សេចក្តីសម្រេចថ្ងៃ ០៣ តុលា ២០០៦ ទាក់ទងនឹងអសមត្ថកិច្ចរបស់តុលាការ លើកឡើងដោយក្រុមមេធាវីការពារក្តី អនុលោមតាមមាត្រា ១៩-២ នៃលក្ខន្តិកៈ ថ្ងៃ ១៤ ធ្នូ ២០០៦ កថា. ២៦។ សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង Barayagwiza អង្គជំនុំជម្រះឧទ្ធរណ៍ សេចក្តីសម្រេចថ្ងៃ ០៣ វិច្ឆិកា ១៩៩៩ សំណុំរឿងលេខ ICTR-97-19-A កថា ៧៣។

00422592



៣៧. ក្រុមមេធាវីការពារក្តីបានលើកឡើងអំពី *"ការប្រកាន់ជ្រែករបស់ចៅក្រម Lemonde ក្នុងការងាររបស់លោក Bastinក្នុងការវាយតម្លៃរបស់គាត់ទៅលើលោក Heder"*។ ទាក់ទងនឹងចំណុចនេះ សហចៅក្រមជាតិមិនមានអ្វីដែលត្រូវលើកឡើងនោះទេ។ សហចៅក្រមអន្តរជាតិវិញយល់ឃើញថា គេមិនត្រូវលើកឡើងអំពីខ្លឹមសារនៃការវាយតម្លៃលើការងាររបស់លោក Heder នោះទេ ព្រោះវាមិនមានជាប់ពាក់ព័ន្ធជាមួយនឹងសិទ្ធិរបស់ភាគីទាល់តែសោះ ហើយសហចៅក្រមអន្តរជាតិអាចត្រឹមតែលើកឡើងអ្វីដែលមេធាវីការពារក្តីបានបញ្ជាក់ថា *"វាប្រាកដណាស់ថា ការវាយតម្លៃលើការងារត្រូវតែឆ្លុះបញ្ចាំងពីភាពស្មោះ ត្រង់របស់អ្នកវាយតម្លៃ ដោយផ្អែកលើព័ត៌មានដែលគាត់មាន"*[31]។ ប៉ុន្តែ សហចៅក្រមអន្តរជាតិសូមរំលឹកថា ការវាយតម្លៃលើការងាររបស់បុគ្គលិកខាងអន្តរជាតិជាសមត្ថកិច្ចរបស់ប្រធានស្ថាប័ន (នៅក្នុងករណីនេះគឺ ចៅក្រមស៊ើបអង្កេតអន្តរជាតិ) ហើយវាមិនមែនជាសមត្ថកិច្ចរបស់អន្តរការីនោះទេ (លោក Bastin)។ ដូច្នេះការចោទប្រកាន់ទាក់ទងនឹង "ការជ្រៀតជ្រែកចូលក្នុងកិច្ចការ" គ្មានមូលដ្ឋានត្រឹមត្រូវនោះទេ។

*ទាក់ទងនឹងសន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រី*

៣៨. ការកត់សម្គាល់ជាទូទៅរបស់ក្រុមមេធាវីការពារក្តីចំពោះសន្ទរកថារបស់សម្តេចនាយករដ្ឋមន្ត្រី ឬ បរិបទនៅក្នុងប្រទេសកម្ពុជាដែលថានឹងមិនអនុញ្ញាតឱ្យមានទំនុកចិត្តលើការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌នោះ មិនត្រូវបានបង្ហាញដោយឧទាហរណ៍ជាក់ស្តែងនៃសេចក្តីសម្រេច ឬកិច្ចផ្សេងៗរបស់ចៅក្រម ដែលថាសេចក្តីសម្រេច ឬ កិច្ចនានារបស់ចៅក្រមទាំងនោះអាចត្រូវបានធ្វើឡើងក្រោមស្ថានភាពដែលគេអាចរិះគន់បានខាងទស្សនៈតុលាការសុទ្ធសាធ។ ដូចមានបញ្ជាក់ខាងលើ នៅក្នុងកថាខណ្ឌ ១៨ រួចហើយ ការកត់សម្គាល់របស់ក្រុមមេធាវីការពារក្តីនេះ ជួនកាលមានលក្ខណៈមិនស៊ីសង្វាក់គ្នា និងមិនច្បាស់លាស់។ ដូច្នេះវាមិនអាចជាមូលហេតុនៃការផ្អាកដំណើរការនីតិវិធីនោះទេ។

*ទាក់ទងនឹងសេចក្តីសម្រេចលើឃ្លាំងផ្ទុកឯកសាររួម (SMD)*

៣៩. ក្រុមមេធាវីការពារក្តីបានលើកឡើងអំពីសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងការស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម និងអំពីសំអាងហេតុនៃសេចក្តី

---

[31] D264 ពាក្យបណ្តឹងសុំផ្អាកដំណើរការនីតិវិធី កថា. ៤៣

សម្រេចលើបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះ ដើម្បីជាភស្តុតាងបញ្ជាក់អំពីភាពលំអៀងរបស់សហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែ ជាក់ស្តែងណាស់ ក្រុមមេធាវីការពារក្តីបានយល់ខុស ចំពោះសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ព្រោះពួកគេបានប្រើប្រាស់ពាក្យថា *"មិនមានគោលការណ៍នៃភាពគ្រប់គ្រាន់នៃភស្តុតាង"*។

៤០. វាមិនមានការខ្វែងគ្នាណាមួយរវាងអ្វីដែលសម្រេចដោយអង្គបុរេជំនុំជម្រះ និងអ្វីដែលសរសេរដោយសហចៅក្រមស៊ើបអង្កេតនោះទេ។ ហេតុផលដ៏សាមញ្ញមួយគឺថា សេចក្តីសម្រេចទាំងពីរនេះបានពិនិត្យទៅលើបញ្ហាពីរដាច់ដោយឡែកពីគ្នា៖ អង្គបុរេជំនុំជម្រះបានរៀបរាប់អំពីដំណើរការនីតិវិធីទៅតាមលំដាប់ពេលវេលានៃការបិទកិច្ចស៊ើបសួរ ចំណែកឯសហចៅក្រមស៊ើបអង្កេតវិញបានពិនិត្យទៅលើហេតុផលដែលអាចនាំឱ្យ *"មានការពិចារណាថាកិច្ចស៊ើបសួរត្រូវបញ្ចប់"* ស្របទៅតាមវិធាន ៦៦(១) នៃវិធានផ្ទៃក្នុង។ បញ្ហាអាចបណ្តាលមកពីហេតុដែលថាសហចៅក្រមស៊ើបអង្កេតប្រហែលជាមិនបានពន្យល់ឱ្យបានច្បាស់លាស់អំពីអ្វីដែលចង់និយាយពី *"គោលការណ៍នៃភាពគ្រប់គ្រាន់នៃភស្តុតាង"*។ ពិតមែនហើយ មិនមានពេលណាមួយ ដែលសហចៅក្រមស៊ើបអង្កេតមានចេតនាមិនគោរពតាមនីតិវិធី ដែលតម្រូវឱ្យមានការប្រកាសអំពីការបិទកិច្ចស៊ើបសួរ មុននឹងប្រមូលបានការកត់សម្គាល់នានារបស់ភាគី និងមុនការពិចារណាលើគ្រប់ភស្តុតាងទាំងអស់ ដែលរួមទាំងភស្តុតាងដោះបន្ទុក ដើម្បីនឹងវាយតម្លៃអំពីភាពគ្រប់គ្រាន់នៃភស្តុតាងនោះទេ។ សហចៅក្រមស៊ើបអង្កេតគ្រាន់តែចង់ព្យាយាមធ្វើការពន្យល់ថា មុននឹងមានការប្រកាសបិទកិច្ចស៊ើបសួរ គេចាំបាច់ត្រូវពិនិត្យ និងវាយតម្លៃទៅលើភស្តុតាងដែលមានក្នុងសំណុំរឿង និងភស្តុតាងនានាដែលប្រមូលបាន[32]។ បន្ទាប់ពីបានពិនិត្យលើភស្តុតាងដែលមានក្នុងសំណុំរឿងទាំងអស់ និង នៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ថា អាចនឹងត្រូវចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចត្រូវប្រាប់អំពីរឿងនេះដល់គ្រប់ភាគី បើពុំនោះសោតកិច្ចស៊ើបសួរមិនអាចនឹងត្រូវបានបញ្ចប់បាននោះទេ។ នេះហើយ ជាខ្លឹមសារពិតប្រាកដនៃ *"គោលការណ៍នៃភាពគ្រប់គ្រាន់នៃភស្តុតាង/Principe de la suffisance des charges"* ចំណែកឯ *"គោលការណ៍នៃភាពអស់សេចក្តីវិញ/Principe d'exhaustivité"* គឺអាចនាំទៅរកស្ថានភាពដែលមិនសមស្រប។ ដូច្នេះវាជាការមិនសមហេតុ

---

[32] នេះគឺជាការវិភាគរបស់អង្គបុរេជំនុំជម្រះផងដែរ៖ **សូមអានសាលដីកាលើសំណើនិតចិត្តរបស់ អៀង សារី ចំពោះសហចៅក្រមស៊ើបអង្កេត Marcel Lemonde ៩ ធ្នូ ២០០៩ កថាខណ្ឌទី២៤** ERN 00407723-00407724 ។

ផលនោះទេ ដែលអះ អាងថាសេចក្ដីសម្រេចនេះជាភស្តុតាងនៃភាពលំអៀងរបស់សហចៅក្រមស៊ើបអង្កេត។

*ទាក់ទងនឹងដីកាសម្រេចបន្តឃុំខ្លួន អៀង ធីរិទ្ធ*

៤១. ក្រុមមេធាវីការពារក្ដីបានជំទាស់ទៅនឹងសំអាងហេតុនៃការបន្តការឃុំខ្លួន ដែលសម្រេចដោយសហចៅក្រមស៊ើបអង្កេត៖ *"សហចៅក្រមស៊ើបអង្កេតមិនបានប្រើប្រាស់ភាសាដូចគ្នា"* ទាក់ទងនឹងការរៀបរាប់អំពីភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ដូច្នេះត្រង់ចំណុចនេះ សហចៅក្រមស៊ើបអង្កេតបានបង្ហាញអំពីភាពលំអៀង។ វាជាការសមហេតុផលហើយ ដែលក្រុមមេធាវីការពារក្ដីបានរិះគន់លើសេចក្ដីសម្រេចដែលខ្លួនបានធ្វើបណ្ដឹងឧទ្ធរណ៍ ប៉ុន្តែវាជាការគួរឲ្យភ្ញាក់ផ្អើលដែលក្រុមមេធាវីការពារក្ដីងឿងឆ្ងល់ចំពោះបញ្ហាដែលថា សេចក្ដីសម្រេចនេះបានផ្ដោតជាសំខាន់លើភស្តុតាងដាក់បន្ទុក ដែលចាំបាច់ដល់ការផ្ដល់យុត្តិកម្មចំពោះការឃុំខ្លួន ដោយបានបង្ហាញថាភស្តុតាងទាំងនោះមានលក្ខណៈធ្ងន់ធ្ងរជាងភស្តុតាងដោះបន្ទុក។ សូមបញ្ជាក់ថា ប្រសិនបើសហចៅក្រមស៊ើបអង្កេតយល់ថា វាមិនមែនបែបនោះទេ ម្ល៉េះសហចៅក្រមស៊ើបអង្កេតសម្រេចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំរួចស្រេចទៅហើយ។ អព្យាក្រឹត្យភាពរបស់ចៅក្រម មិនមែនមិនអនុញ្ញាតឲ្យចៅក្រមធ្វើការពិនិត្យលើទំហំនៃភស្តុតាង នៅពេលដែលចៅក្រមត្រូវសម្រេចលើការឃុំខ្លួននោះទេ។ ក្នុងករណីដែលមានការភ័ន្តច្រលំជាយថាហេតុលើការវាយតម្លៃទំហំភស្តុតាងទាំងនោះ គេអាចប្រើប្រាស់ផ្លូវនៃបណ្ដឹងឧបាស្រ័យ ដើម្បីដោះស្រាយបញ្ហានៃការភ័ន្តច្រលំនេះ ដូច្នេះគ្មានហេតុផលណាមួយដែលត្រូវពិនិត្យលើភាពលំអៀង ឬមិនលំអៀងនោះឡើយ[33]។

**សេចក្ដីសន្និដ្ឋានបញ្ចប់**

៤២. យោងតាមការរៀបរាប់មកខាងលើនេះ មិនមានអ្វីដែលអាចផ្ដល់យុត្តិកម្មលើបណ្ដឹងសុំមោឃភាពកិច្ចនីតិវិធីចំពោះមុខអង្គបុរេជំនុំជម្រះ និងបណ្ដឹងសុំផ្អាកដំណើរការនីតិវិធីនោះឡើយ ដោយហេតុថា មិនមានវិការៈនៃនីតិវិធីណាមួយត្រូវបានរកឃើញ និងដោយហេតុថា ទាំងវិធាន

---

[33] **សូមអានសាលដីកាលើសំណើមិតចិត្តរបស់ ខៀវ សំផន ចំពោះសហចៅក្រមស៊ើបអង្កេត Marcel Lemonde ១៤ ធ្នូ ២០០៩ កថាខណ្ឌទី៣៤-៣៥** ERN 004414122 ។

00422595



២១ នៃវិធានផ្ទៃក្នុង និងសិទ្ធិរបស់ជនត្រូវចោទដែលមានចែងក្នុងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនត្រូវបានរំលោភបំពាននោះ ពាក្យបណ្តឹងទាំងពីរនេះគួរត្រូវបដិសេធចោល។

## អាស្រ័យហេតុនេះ

**សម្រេច** មិនធ្វើពាក្យបណ្តឹងសុំមោឃភាពកិច្ចនីតិវិធីទៅអង្គបុរេជំនុំជម្រះ

**សម្រេច** មិនមានការផ្អាកដំណើរការនីតិវិធី

**សម្រេច** បដិសេធចោលពាក្យបណ្តឹងទាំងនេះ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៩

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**

យូ ប៊ុនឡេង